គ្រឿងឧបករណ៍នៃប្រព័ន្ធបញ្ជូន និងទទួលរលកសញ្ញា Dell Wireless WLAN Card ត្រូវបានគេបង្កើតឡើង ដើម្បីដាក់ ឱ្យធ្វើអន្តរប្រតិបត្តិការជាមួយគ្រឿងឧបករណ៍នៃប្រព័ន្ធបញ្ជូន និងទទួលរលកសញ្ញា Wireless LAN ដែលផ្អែកលើ បច្ចេកវិទ្យាវិទ្យុផ្សព្វផ្សាយ ដែលមានវិសាលគមរីកជាលំដាប់លំដោយផ្ទាល់ DSSS និងការបែងចែកប្រេកង់ស៊ើត្រឹមត្រូវ តាមបទដ្ឋាន OFDM និងគោរពតាមបទដ្ឋាន ដូចខាងក្រោម:

- IEEE 802.11a បទដ្ឋានគឺ 5 GHz Wireless LAN
- IEEE 802.11b-1999 បទដ្ឋានគឺ 2.4 GHz Wireless LAN
- IEEE 802.11g បទដ្ឋានគឺ 2.4 GHz Wireless LAN
- ការបញ្ជាក់ពីប្រព័ន្ធ បញ្ជូន និងទទួលរលកសញ្ញា Wi-Fi ដូចដែលបានកំណត់ដោយប្រព័ន្ធ WECA (Wireless Ethernet Compatibility Alliance)

## សុវត្ថិភាព

គ្រឿងឧបករណ៍នៃប្រព័ន្ធបញ្ជូន និងទទួលរលកសញ្ញា Dell Wireless WLAN Card ក៏ដូចជាគ្រឿងឧបករណ៍នៃប្រព័ន្ធបញ្ជូន និងទទួលរលកសញ្ញាដទៃទៀតដែរ ដែលបញ្ចេញថាមពលអេឡិចត្រូម៉ាញ៉េទិចប្រេកង់ស៊ីវិទ្យុ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏រិតថាមពលដែលបានបញ្ចេញ តាមរយៈគ្រឿងឧបករណ៍នេះ គឺខ្សោយជាងថាមពលអេឡិចត្រូម៉ាញ៉េទិច ដែលបញ្ចេញតាមរយៈគ្រឿងឧបករណ៍ នៃប្រព័ន្ធបញ្ជូន និងទទួលរលកសញ្ញាផ្សេងៗទៀត ដូចជាទូរស័ព្ទចល័តជាដើម ។ គ្រឿងឧបករណ៍នៃប្រព័ន្ធបញ្ជូន និងទទួលរលកសញ្ញា Dell Wireless WLAN Card ដំណើរការតាមគោលការណ៍ណែនាំ ដែលមាននៅក្នុងប្រេកង់ស៊ីសុវត្ថិភាពវិទ្យុ និងអនុសាសន៍នានា។ បទដ្ឋាន និងអនុសាសន៍ទាំងនេះ បង្ហាញឱ្យឃើញនូវការព្រមព្រៀងរួមគ្នារបស់ក្រុមអ្នកវិទ្យាសាស្ត្រ និងលទ្ធផលបានមកពីការពិភាក្សារបស់ក្រុម និងគណៈកម្មាធិការអ្នកវិទ្យាសាស្ត្រដែលត្រួតពិនិត្យ និងបកស្រាយឯកសារស្រាវជ្រាវទូលំទូលាយ ។ នៅក្នុងស្ថានភាពខ្លះ ឬក្នុងកាលៈទេសៈខ្លះ ការប្រើប្រាស់គ្រឿងឧបករណ៍នៃប្រព័ន្ធបញ្ជូន និងទទួលរលកសញ្ញា Dell Wireless WLAN Card ត្រូវ អនុវត្តតាមលក្ខខណ្ឌរបស់ម្ចាស់អ្នកបង្កើត ឬតំណាងទទួលខុសត្រូវរបស់ស្ថាប័នដែលមានសិទ្ធិ ។

ឧទាហរណ៍នៃស្ថានភាពបែបនេះមានដូចខាងក្រោម:

- ការប្រើប្រាស់គ្រឿងឧបករណ៍នៃប្រព័ន្ធបញ្ជូន និងទទួលរលកសញ្ញា Dell Wireless WLAN Card ពេលជិះ យន្តហោះ ឬ

- ការប្រើប្រាស់គ្រឿងឧបករណ៍នៃប្រព័ន្ធបញ្ជូន និងទទួលរលកសញ្ញា Dell Wireless WLAN Card នៅក្នុង ស្ថានភាពណាមួយបង្កឱ្យមានគ្រោះថ្នាក់រំខានដល់គ្រឿងឧបករណ៍ឬសេវាផ្សេងៗទៀត ត្រូវគេដឹង ឬកំណត់ថា ជាគ្រោះថ្នាក់ ។

ប្រសិនបើអ្នកមិនយល់ច្បាស់អំពីគោលការណ៍អនុវត្តការប្រើប្រាស់គ្រឿងឧបករណ៍ នៃប្រព័ន្ធបញ្ជូន និងទទួលរលកសញ្ញា Dell Wireless WLAN Card នៅក្នុងស្ថាប័ន ឬស្ថានភាពជាក់លាក់ណាមួយទេ (ដូចជានៅក្នុងព្រលានយន្តហោះ) អ្នកត្រូវតែសុំការអនុញ្ញាតដើម្បីប្រើប្រាស់ មុននឹងដំណើរការគ្រឿងឧបករណ៍នោះ ។

**បម្រាមចំពោះការដាក់គ្រឿងឧបករណ៍នៃប្រព័ន្ធបញ្ជូន និងទទួលរលកសញ្ញា ជិតគ្រឿងផ្ទុះ:**

សូមកុំប្រត្តិបតិការគ្រឿងវិទ្យុទាក់ទងដែលអាចយកតាមខ្លួនបាន(ដូចជាគ្រឿងឧបករណ៍នៃប្រព័ន្ធបញ្ជូន និងទទួលរលកសញ្ញា) នៅក្បែរធុងផ្ទុកជាតិផ្ទុះដែលមិនបានបិទជិត ឬស្ថានភាពដែលមានជាតិផ្ទុះឡើយ លុះត្រាគ្រឿងឧបករណ៍នោះបានកែប្រែបញ្ជាក់ឱ្យប្រើនៅក្នុងស្ថានភាពបែបនោះ ។

**ប្រយ័ត្នចំពោះការប្រើប្រាស់គ្រឿងឧបករណ៍វិទ្យុទាក់ទងលើយន្តហោះ:**

បទបញ្ញត្តិរបស់ **FCC** និង **FAA** បានហាមឃាត់មិនឱ្យប្រត្តិបតិការគ្រឿងឧបករណ៍ នៃប្រព័ន្ធបញ្ជូន និងទទួលរលកសញ្ញា Dell Wireless WLAN Card នៃប្រេ្វកង់សវិទ្យុ ពីព្រោះលេកសញ្ញារបស់ពួកវាអាចរំខានដល់គ្រឿងឧបករណ៍សំខាន់ៗរបស់យន្តហោះ ។

## បទបញ្ញត្តិព័តិមាន

គ្រឿងឧបករណ៍នៃប្រព័ន្ធបញ្ជូន និងទទួលរលកសញ្ញា Dell Wireless WLAN Card ត្រូវបានគេតម្លើង និងប្រើប្រាស់ក្នុងលក្ខខណ្ឌតឹងរឹង ដោយយោងទៅតាមការណែនាំរបស់ក្រុមហ៊ុនផលិត ដែលមាននៅក្នុងឯកសារសំរាប់អ្នកប្រើប្រាស់ ដែលមានភ្ជាប់ជាមួយគ្រឿងឧបករណ៍ ។ ក្រុមហ៊ុន Dell មិនទទួលខុសត្រូវចំពោះការរំខានដល់ទូរទស្សន៍ ឬវិទ្យុណាមួយ ដែលបណ្តាលមកពីការកែប្រែដោយមិនមានការអនុញ្ញាតនូវគ្រឿងឧបករណ៍ ដែលដាក់ភ្ជាប់ជាមួយគ្រឿងឧបករណ៍ Dell Wireless WLAN Card ឬគ្រឿងបន្លាស់ ឬគ្រឿងភ្ជាប់ខ្សែចរន្ត និងគ្រឿងឧបករណ៍ភ្ជាប់ផ្សេងទៀត ក្រៅពីគ្រឿងឧបករណ៍ដែលមានការបញ្ជាក់ពីក្រុមហ៊ុន Dell ឡើយ ។ ការកែប្រែការរំខាន ដែលបណ្តាលមកពីការកែប្រែគ្រឿងបន្លាស់ ឬគ្រឿងភ្ជាប់ទៅនឹងខ្សែចរន្ត ដោយមិនមានការអនុញ្ញាត បែបនេះ គឺជាទំនួលខុសត្រូវរបស់អ្នកប្រើប្រាស់ ។ ក្រុមហ៊ុន Dell និងអ្នកលក់បន្ត ឬអ្នកចែកចាយ

ដែលមានការ អនុញ្ញាតត្រឹមត្រូវមិនទទួលខុសត្រូវចំពោះការខូចខាតណាមួយ ឬការរំលោភបំពានលើច្បាប់រដ្ឋាភិបាល ដែលអាចនឹង កើតឡើង ដោយសារតែអ្នកប្រើប្រាស់ មិនបានអនុវត្តតាមការណែនាំនេះ ។

## ការយល់ព្រមឱ្យប្រើប្រាស់វិទ្យុ

ជាការសំខាន់ណាស់ដែលត្រូវប្រាកដថា អ្នកប្រើប្រាស់គ្រឿងឧបករណ៍វិទ្យុរបស់អ្នកនៅក្នុងប្រទេស ដែលជាទីកន្លែង ដែលគេអនុញ្ញាតឱ្យប្រើប្រាស់ឧបករណ៍នេះ ។ ដើម្បីកំណត់ថាតើគេអនុញ្ញាតឱ្យប្រើគ្រឿងឧបករណ៍របស់អ្នកនៅ ក្នុងប្រទេសណាមួយ ឬអត់ សូមពិនិត្យមើលថាតើលេខប្រភេទវិទ្យុ ដែលបានបោះពុម្ពលើស្លាកសញ្ញានៃគ្រឿង ឧបករណ៍របស់អ្នក ឬរៀបរាប់នៅក្នុងតារាងក្នុងការយល់ព្រមឱ្យប្រើប្រាស់វិទ្យុ បានចុះផ្សាយនៅក្នុងអាសយដ្ឋានជាទូទៅ របស់ ក្រុមហ៊ុន Dell http://support.dell.com ដែរឬទេ ។